## ១.វិធីកំចាត់សត្វចង្រៃដែលមាននៅក្នុងទឹកស្រះ :

-បញ្ឈប់ការដាក់ជី និងចំណីមួយរយៈពេលខ្លី ។

-យកប្រេងកាត ៤-៥ ស្លាបព្រាបាយ ចាក់ទៅក្នុងស្រះនៅពីលើទិសខ្យល់ ។

## ២.វិធីការពារត្រីកាចកុំឱ្យមានក្នុងស្រះព្រោះវាស៊ីត្រីចិញ្ចឹម :

-មុនដាក់ត្រីចិញ្ចឹមត្រូវកំចាត់ពួកត្រីកាចដោយប្រើកំបោរស ។



*របៀបរៀបចំស្រះមុនពេលដាក់កូនត្រីចិញ្ចឹម*

-ស្រះត្រូវមានភ្លឺខ្ពស់ និងមាំល្អ ។

-ធ្វើអន្លង់នៅក្បែរភ្លឺស្រះ ។

-ប្រើព្រួលឫស្សីធ្វើជារនាំងការពារនៅតាមភ្លឺស្រះ បើអាចធ្វើបាន ។

## ៣.ការបង្កើនទិន្នផលត្រី បន្ថយការចំណាយ :

ភាគច្រើនកសិករមានស្រះត្រីនៅក្បែរស្រែ ដូចនេះដើម្បីបង្កើនទិន្នផលត្រី និងបន្ថយនូវការចំណាយថវិកាលើចំណីត្រី អ្នកត្រូវតភ្ជាប់ស្រះទៅនឹងស្រែដោយប្រឡាយព្រោះថា :

-ត្រីវាជួយស៊ីសត្វល្អិតផ្សេងៗ និងរុក្ខជាតិតូចៗនៅក្នុងស្រែដែលវាធ្វើអោយប៉ះពាល់ដល់ការលូតលាស់របស់ដំណាំស្រូវ ។

-នៅក្នុងវាលស្រែសំបូរចំណីច្រើនអាចបន្ថយពេលវេលា និងការចំណាយទៅលើចំណីត្រី ។

-រីឯលាមកត្រីជាជីសំរាប់បង្កើននូវទិន្នផលស្រូវ ។

-ធ្វើអោយដីស្រែកើនគុណភាព ដោយសារសកម្មភាពត្រីឈ្លួសដី កកាយដីក្នុងស្រែដើម្បីរកចំណី។ ដូច្នេះវាអាចកើនផលទាំងពីរមុខ គឺស្រូវ និងត្រី ។

ដូចនេះមុននឹងចិញ្ចឹមត្រីក្នុងស្រែ អ្នកត្រូវរៀបចំភ្លឺស្រែដោយជីកប្រឡាយជុំវិញស្រែ ដោយយកដីទប់ទំនប់អោយបានមាំនិងខ្ពស់ ។ ប្រឡាយត្រូវជីកអោយបានជំរៅកន្លះម៉ែត្រ និងទទឹងកន្លះម៉ែត្រទៅ ០,៧៥ ម៉ែត្រ ពីទំនប់ភ្លឺស្រែ ។ ចំនួនកូនត្រីដាក់ចិញ្ចឹមក្នុងស្រែគឺ ១ ក្បាលក្នុង ១ ម៉ែត្រក្រឡានៃផ្ទៃស្រែនិងប្រឡាយ ហើយកូនត្រីដាក់ចិញ្ចឹមត្រូវដាក់ក្រោយស្ទូងរយៈពេល២សប្តាហ៍ ទើបព្រលែងកូនត្រីអោយចូលក្នុងស្រែ រហូតដល់ពេលប្រមូលស្រូវរួច បន្ទាប់ពីទឹកស្រែរីង អ្នកត្រូវប្រមូលត្រីដាក់ទៅក្នុងស្រះចិញ្ចឹមបន្តទៀត ។



*ក្រោយពីទឹកស្រែរីង កសិករប្រមូលត្រីដាក់ទៅក្នុងស្រះចិញ្ចឹមបន្ត*

បើអ្នកចង់ឱ្យការចិញ្ចឹមត្រីរបស់អ្នកទទួលបានជោគជ័យ អ្នកត្រូវអនុវត្តតាមចំណុចដូចតទៅ :

-ការសំអាតស្រះមុនពេលដាក់ត្រីចិញ្ចឹម ។

-ក្នុងស្រះត្រីរបស់អ្នកត្រូវការពារកុំអោយមានត្រីកាចដូចជា ត្រីរ៉ស់ ត្រីអណ្តែងជាដើម ។

-ដាក់ជីជាប្រចាំនូវប្រភេទជីលាមកសត្វ ជីរុក្ខជាតិបៃតង ជីអ៊ុយរ៉េ និងជីដេអាប៉េ ដើម្បីធ្វើអោយទឹកមានពណ៌បៃតងសំបូរចំណីត្រី ។



*ការផ្តល់ចំណីត្រីបន្ថែមក្រៅពីប្លុងគុងដែលមាន នៅក្នុងស្រះត្រី*

-ស្រះមិនស្ថិតនៅក្នុងម្លប់មានន័យថា (ស្រះមានពន្លឺថ្ងៃចាំងចូលបានគ្រប់គ្រាន់) ។

-ដាក់ចិញ្ចឹមនូវប្រភេទត្រី ដែលមិនស៊ីសាច់ជាអាហារ មានប្រវែងពី ៣ ថ្នាំងដៃឡើងទៅ ។

-ការចិញ្ចឹមត្រីក្នុងស្រះមានភ្ជាប់ប្រឡាយទៅស្រែ ជួយឱ្យត្រីឆាប់ធំធាត់រហ័ស ហើយអាចបន្ថយការចំណាយលើការផ្តល់ចំណី ។

-ស្រះចិញ្ចឹមត្រីអាចធានាទឹកបានរយៈពេលយ៉ាងតិច ៦ ខែ ឡើងទៅ ។

# វិធីកំចាត់សត្វចង្រៃនិង ការពារត្រីកាចកុំឱ្យមានក្នុងស្រះ





គំរោងឥណទានកម្មវិធី ធនាគារ អភិវឌ្ឍន៍ អាស៊ី (ADB) លេខ 1445_CAM (SF)
នាយកដ្ឋាន ផ្សព្វផ្សាយកសិកម្ម
លេខ : ១៥ ឆ្នាំ ២០០៣